# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ឯកសារណែនាំ
## ស្តីពី
## ការគ្រប់គ្រង និងដំណើរការប្រតិបត្តិ ការផ្តល់សេវាបណ្តុះបណ្តាលជំនាញបន្ថែម ផ្នែកស្នែម នៅវិទ្យាល័យធនធាន

នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ

គម្រោងអភិវឌ្ឍវិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ (USESDP II) ឆ្នាំ២០២១

# បុព្វកថា

សកលលោកមានការវិវត្តន៍ឥតឈប់ឈរផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដែលទាមទារឱ្យមនុស្សអភិវឌ្ឍខ្លួនជាប្រចាំ ដើម្បីចូលរួមក្នុងការប្រកួតប្រជែង។ ការអប់រំជាវិស័យគន្លឹះមួយក្នុងការចូលរួមចំណែកអភិវឌ្ឍន៍ធនធានមនុស្ស សំដៅជំរុញឱ្យសង្គមនិងសេដ្ឋកិច្ចរីកចម្រើន។ នាដើមសតវត្សរ៍ទី២១នេះ សង្គមនិងសេដ្ឋកិច្ចឈានដល់បរិបទថ្មីដែលមិនធ្លាប់មានកន្លងមក ដោយសារពិភពលោកកាន់តែបើកចំហរ ការប្រកួតប្រជែងកាន់ស្រួចស្រាវ វិស័យបច្ចេកវិទ្យានិងវិទ្យាសាស្ត្រកាន់តែទំនើប។ ទាំងនេះជាហេតុផលដែលទាមទារឱ្យមានការអភិវឌ្ឍធនធានមនុស្សប្រកបដោយសមត្ថភាពនិងគុណភាព ដើម្បីឆ្លើយតបនឹងបរិបទថ្មី និងការប្រកួតប្រជែងក្នុងសង្គម និងសេដ្ឋកិច្ចពិភពលោក។

ឆ្លើយតបទៅនឹងបរិបទនៃការរីកចម្រើនរបស់សង្គមនិងសេដ្ឋកិច្ចថ្មីនេះ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំបង្កើតកម្មវិធីអប់រំជំនាញបន្ថែម ផ្នែកស្ទែម(STEM SKILL Extra Curricula ) ក្នុងគោលបំណងបណ្តុះបណ្តាលសិស្សដែលកំពុងសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិ ឱ្យមានជំនាញមួយយ៉ាងតិច ក្រោយបញ្ចប់ការសិក្សានៅកម្រិតទុតិយភូមិ ស្របតាមទេពកោសល្យរបស់ខ្លួន តាមតម្រូវការទីផ្សារនិងសហគមន៍ និងជួយគាំទ្របន្តការសិក្សា។ កម្មវិធីនេះ រៀបចំឡើងដើម្បីធានាឱ្យអ្នកសិក្សាមានសមត្ថភាពគ្រប់គ្រាន់ដែលអាចបំពេញការងារបាន យល់ដឹងពីធុរកិច្ច មានគំនិតផ្តួចផ្តើម គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងការតាំងចិត្តខ្ពស់ក្នុងការបង្កើតឱ្យមានសមិទ្ធផលថ្មី ក្នុងការចូលរួមចំណែកអភិវឌ្ឍគ្រួសារ និងជំរុញកំណើនសេដ្ឋកិច្ចគ្រួសារក៏ដូចជាសង្គមជាតិ។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមថាអង្គភាពពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នឹងចូលរួមសហការគាំទ្រក្នុងការអនុវត្តកម្មវិធីអប់រំជំនាញបន្ថែម ផ្នែកស្ទែម (STEM SKILL Extra Curricula) ដើម្បីចូលរួមអភិវឌ្ឍន៍យុវជន ឆ្លើយតបនឹងការវិវត្តន៍របស់ពិភពលោក។ ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណដោយស្មោះចំពោះធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលបានគាំទ្រថវិកាក្នុងការអនុវត្តកម្មវិធីនេះ ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍សមត្ថភាពយុវជនកម្ពុជា និងសូមកោតសរសើរដល់បុគ្គលិកអប់រំទាំងអស់ដែលយកអស់កម្លាំងកាយ និងប្រាជ្ញាស្មារតី កសាងកម្មវិធីនេះ។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែ ទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# មាតិកា


បុព្វកថា ........ ii

១. សេចក្ដីផ្ដើម ........ 1

២. គោលបំណង ........ 1

៣. សមាសភាព និងតួនាទី ភារកិច្ចរបស់គណៈកម្មការដឹកនាំគ្រប់គ្រងការបណ្ដុះបណ្ដាលជំនាញបន្ថែមផ្នែកស្វែម ........ 2

៣.១ សមាសភាពគណៈកម្មការ ........ 2

៣.២ តួនាទី និងភារកិច្ចគណៈកម្មការ ........ 2

៣.៣ តួនាទី និងភារកិច្ចរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី/ខេត្ត ........ 2

៣.៤ តួនាទី និងភារកិច្ចរបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ ........ 3

៣.៥ តួនាទី និងភារកិច្ចរបស់ នាយក និងនាយករងវិទ្យាល័យធនធាន ........ 3

៣.៦ តួនាទី និងភារកិច្ចរបស់អ្នកផ្ដល់សេវាបណ្ដុះបណ្ដាល ........ 3

៤. ដំណើរការបណ្ដុះបណ្ដាលជំនាញបន្ថែមផ្នែកស្វែម ........ 4

៤.១ ការផ្ដល់សេវាបណ្ដុះបណ្ដាល ........ 4

៤.២ លក្ខណៈសម្បត្តិអ្នកផ្ដល់សេវាបណ្ដុះបណ្ដាល ........ 4

៤.៣ ការជ្រើសរើសសិស្សចូលរៀនជំនាញ ........ 4

៤.៣.១ លក្ខខណ្ឌនៃការជ្រើសរើស ........ 4

៤.៣.២ ការផ្សព្វផ្សាយ ........ 5

៤.៣.៣ របៀបនៃការជ្រើសរើស ........ 5

៥. ក្របខណ្ឌការអនុវត្តកម្មវិធីសិក្សាជំនាញបន្ថែមផ្នែកស្វែម ........ 5

៥.១ កម្មវិធីសិក្សាជំនាញបន្ថែមផ្នែកស្វែម ........ 5

៥.២ វិធីសាស្ត្របណ្ដុះបណ្ដាលជំនាញបន្ថែមផ្នែកស្វែម ........ 6

៥.៣ ការវាយតម្លៃកម្មវិធីសិក្សាជំនាញបន្ថែមផ្នែកស្វែម ........ 7

៥.៣.១ ការវាយតម្លៃការបង្រៀននិងរៀន ........ 7

៥.៣.២ ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ........ 7

៦. ថវិកាគាំទ្រការបណ្ដុះបណ្ដាល ........ 8

៦.១ ការរៀបចំផែនការថវិកាប្រចាំឆ្នាំ ........ 9

៦.២ ការទូទាត់ចំណាយ ........ 9

៧. យន្តការអនុវត្ត ........ 9

៨. ផែនការសកម្មភាពដំណើរការប្រតិបត្តិការផ្ដល់សេវាបណ្ដុះបណ្ដាលជំនាញបន្ថែមផ្នែកស្វែម នៅវិទ្យាល័យធនធាន ........ 10

៩. ការពិនិត្យតាមដាន និងវាយតម្លៃ ........ 11

១០. យន្តការអនុវត្តការងារបរិបទជំងឺកូវីដ-១៩ .......... 11
១១. សន្និដ្ឋាន .......... 12
បទានុក្រម .......... 13
ឧបសម្ព័ន្ធ .......... 14
(ឧបសម្ព័ន្ធទី១) .......... 15
(ឧបសម្ព័ន្ធទី២) .......... 16
(ឧបសម្ព័ន្ធទី៣) .......... 17
(ឧបសម្ព័ន្ធទី៤) .......... 18
(ឧបសម្ព័ន្ធទី៥) .......... 19
(ឧបសម្ព័ន្ធទី៦) .......... 20
(ឧបសម្ព័ន្ធទី៧) .......... 21
(ឧបសម្ព័ន្ធទី៨) .......... 22
(ឧបសម្ព័ន្ធទី៩) .......... 25
(ឧបសម្ព័ន្ធទី១០) .......... 28

## ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាមានមហិច្ឆតាក្នុងការផ្លាស់ប្តូរពីប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ នៅក្នុងឆ្នាំ២០៣០ និងក្លាយទៅជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០។ ដើម្បីសម្រេចបំណងនេះ រាជរដ្ឋាភិបាលចាំបាច់ត្រូវជំរុញអភិវឌ្ឍន៍ជំនាញបច្ចេកទេសដល់យុវជន ដើម្បីបង្កើតឱកាសការងារក្នុងការប្រកួតប្រជែង និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព ក្នុងនោះមានការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្សដោយពង្រឹងគុណភាពវិស័យអប់រំ និងជំរុញការបណ្តុះបណ្តាលជំនាញបច្ចេកទេស សម្រាប់យុវជនកម្ពុជា។

ជាមួយគ្នានេះដែរក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩-២០២៣ នូវកម្មវិធីជាអាទិភាពនិងផែនការសកម្មភាពនៅកម្រិតមធ្យមសិក្សា ដោយផ្តោតការយកចិត្តទុកដាក់លើមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យាវិស្វកម្ម និងគណិតវិទ្យា ការផ្តល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស កម្មវិធីបំណិនជីវិតមូលដ្ឋាន ការអប់រំតម្រង់ទិសវិជ្ជាជីវៈ និងប្រឹក្សាអាជីព ដើម្បីផ្សារភ្ជាប់យុវជនទៅនឹងទីផ្សារការងារ។

តាមរយៈក្រសួងអប់រំ យុវជន និងកីឡា ធនាគារអភិវឌ្ឍន៍អាស៊ី(ADB)នឹងផ្តល់ថវិកាគាំទ្រដំណើរការបណ្តុះបណ្តាលសម្រាប់ការសាកល្បងកម្មវិធីបណ្តុះបណ្តាលជំនាញបន្ថែម នៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅតាមវិទ្យាល័យធនធាន ក្នុងគោលបំណងជួយសិស្សឱ្យទទួលបានជំនាញ ដើម្បីបម្រើជីវភាពរស់នៅប្រចាំថ្ងៃ ផ្សារភ្ជាប់ជាមួយចំណង់ចំណូលចិត្ត ទេពកោសល្យរបស់ខ្លួន ស្របតាមតម្រូវការទីផ្សារការងារជាក់ស្តែងនៅក្នុងសហគមន៍ និងជួយគាំទ្របន្តការសិក្សាផងដែរ។ ដើម្បីធានាការអនុវត្តកម្មវិធីនេះបានជោគជ័យ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំឯកសារណែនាំស្តីពី «ការគ្រប់គ្រងនិងដំណើរការប្រតិបត្តិការ ផ្តល់សេវាបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្នែម នៅវិទ្យាល័យធនធាន» ដើម្បីណែនាំ និងផ្សព្វផ្សាយដល់គណៈគ្រប់គ្រង លោកគ្រូអ្នកគ្រូនៅតាមវិទ្យាល័យធនធាន អ្នកពាក់ព័ន្ធ អំពីយន្តការនៃការគ្រប់គ្រងនិងអនុវត្ត និងធ្វើកិច្ចសហការជាមួយសហគ្រាស ឬអ្នកផ្តល់សេវាបណ្តុះបណ្តាល ដើម្បីធានានូវប្រសិទ្ធភាព និងគុណភាពនៃការបណ្តុះបណ្តាលជំនាញ។

## ២. គោលបំណង

ផ្តល់ជំនាញបន្ថែមផ្នែកស្នែមមួយយ៉ាងតិចដល់សិស្ស ដែលកំពុងសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិ ស្របតាមចំណង់ចំណូលចិត្ត ទេពកោសល្យរបស់ខ្លួន ឆ្លើយតបនឹងតម្រូវការទីផ្សារការងារជាក់ស្តែងនៅក្នុងសហគមន៍ និងជួយតម្រង់ទិសការសិក្សារបស់សិស្សផ្នែកស្នែម កាន់ភូមិសិក្សាបន្ទាប់។

# ៣. សមាសភាព និងតួនាទី ភារកិច្ចរបស់គណៈកម្មការដឹកនាំគ្រប់គ្រងការបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្នែម

## ៣.១ សមាសភាពគណៈកម្មការ

គណៈកម្មការដឹកនាំគ្រប់គ្រងការបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្នែម មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - ប្រធាន/អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា | ប្រធាន |
| - ប្រធាន/អនុប្រធានការិ.មធ្យមសិក្សាចំណេះទូទៅ នៃមន្ទីរអយក. | អនុប្រធាន |
| - ប្រធាន/អនុប្រធានការិយាល័យអយក.នៃរដ្ឋបាល ក្រុង/ស្រុក /ខណ្ឌ | សមាជិក |
| - នាយកវិទ្យាល័យធនធាន | សមាជិកប្រចាំការ |
| - នាយករងវិទ្យាល័យធនធាន(០១រូប) | សមាជិក |

## ៣.២ តួនាទី និងភារកិច្ចគណៈកម្មការ

គណៈកម្មការនេះត្រូវអនុវត្តភារកិច្ចដូចខាងក្រោម៖

- ធានាប្រសិទ្ធភាពនិងប្រសិទ្ធផល នៃការបណ្តុះបណ្តាលមុខជំនាញបន្ថែមផ្នែកស្នែម ដល់អ្នកសិក្សា
- គ្រប់គ្រងវគ្គបណ្តុះបណ្តាលនិងយន្តការបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាពខ្ពស់
- គ្រប់គ្រងចំណូលនិងចំណាយលើការបណ្តុះបណ្តាល និងចំណាយចរន្តផ្សេងៗលើដំណើរការបណ្តុះបណ្តាល (មានក្នុងឧបសម្ព័ន្ធទី៣)
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការបណ្តុះបណ្តាលចំនួន០២ដង ទៅនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ នៃក្រសួងអប់រំ យុវជន និងកីឡា (មានក្នុងឧបសម្ព័ន្ធទី២) និងរបាយកាណ៍ពិនិត្យតាមដាននិងវាយតម្លៃលើការអនុវត្តជំនាញបន្ថែមរាល់វគ្គសិក្សា។
- រៀបចំពាក្យសុំចុះឈ្មោះចូលរៀនដល់អ្នកសិក្សា
- រៀបចំនិងរក្សាទុកឯកសារពាក់ព័ន្ធរបស់អ្នកសិក្សា។

## ៣.៣ តួនាទី និងភារកិច្ចរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី/ខេត្ត

មន្ទីរអប់រំ យុវជន និងកីឡារាជធានី/ខេត្តសាម៉ីនីមួយៗជាអង្គភាពគាំទ្រ សម្របសម្រួល និងធានាថាការផ្តល់សេវាបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។ ដូចនេះមន្ទីរសាម៉ីមាន តួនាទីនិងភារកិច្ចដូចខាងក្រោម៖

- បង្កើតគណៈកម្មការគ្រប់គ្រងនិងដឹកនាំដំណើរការបណ្តុះបណ្តាល (ឧបសម្ព័ន្ធទី៥)
- គាំទ្រ សម្របសម្រួល និងជំរុញសកម្មភាពផ្តល់សេវាបណ្តុះបណ្តាលជំនាញស្នែមនៅតាមវិទ្យាល័យគោលដៅ
- ពិនិត្យតាមដាន និងវាយតម្លៃសកម្មភាពបណ្តុះបណ្តាលវគ្គសិក្សានីមួយៗ សំដៅធានាការបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាព

- រៀបចំរបាយការណ៍ពិនិត្យតាមដាននិងវាយតម្លៃការបណ្តុះបណ្តាលតាមវគ្គសិក្សា។

## ៣.៤ តួនាទី និងភារកិច្ចរបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ

ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌសាមីនីមួយៗ ជួយគាំទ្រ សម្របសម្រួលនិងធានាថាការផ្តល់សេវាបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាពនិងតម្លាភាព។ ដូចនេះ ការិយាល័យសាមីមានភារកិច្ចដូចខាងក្រោម៖

- ផ្សព្វផ្សាយការណែនាំនិងសកម្មភាពនៃការផ្តល់សេវាបណ្តុះបណ្តាលជំនាញស្វែមនៅតាមសាលានិងដល់គ្រប់អ្នកពាក់ព័ន្ធ
- សម្របសម្រួលនិងដោះស្រាយបញ្ហាប្រឈមនានា
- សហការនិងជំរុញការគាំទ្រសកម្មភាពនៃការផ្តល់សេវាបណ្តុះបណ្តាលជំនាញស្វែម
- ពិនិត្យតាមដាននិងវាយតម្លៃការគ្រប់គ្រងការបណ្តុះបណ្តាលជំនាញស្វែម។

## ៣.៥ តួនាទី និងភារកិច្ចរបស់ នាយក និងនាយករងវិទ្យាល័យធនធាន

នាយកនិងនាយករងជាអ្នកគ្រប់គ្រងដោយផ្ទាល់លើការផ្តល់សេវាបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្វែមនេះដល់សិស្សានុសិស្សដើម្បីធានាថាការបណ្តុះបណ្តាលប្រកបដោយគុណភាពនិងលទ្ធផលទទួលយកបាន។ ដូចនេះ នាយកនិងនាយករងមានភារកិច្ចដូចខាងក្រោម៖

- ចុះហត្ថលេខាលើកិច្ចសន្យាផ្តល់សេវាបណ្តុះបណ្តាលជាមួយគ្រូបណ្តុះបណ្តាលដោយមានការទទួលស្គាល់ពីគណៈគ្រប់គ្រងមន្ទីរ (មានក្នុងឧបសម្ព័ន្ធទី១)
- រៀបចំថ្នាក់រៀនឱ្យបានសមស្របតាមតម្រូវការ និងចំនួនសិស្សដែលបានកំណត់
- សហការជាមួយគ្រូបណ្តុះបណ្តាល ដើម្បីរៀបចំផែនការ កម្មវិធីសិក្សា និងកាលវិភាគទៅតាមមុខជំនាញនីមួយៗ
- ផ្តល់បន្ទប់ឬទីធ្លាចាំបាច់សម្រាប់ការងារប្រតិបត្តិក្នុងពេលបណ្តុះបណ្តាល
- ចាត់ចែងនិងគ្រប់គ្រងថវិកាបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាពខ្ពស់ តម្លាភាព និងគណនេយ្យភាព
- ពិនិត្យតាមដាន វាយតម្លៃវគ្គបណ្តុះបណ្តាល និងរៀបចំរបាយការណ៍ ផ្អែកលើលទ្ធផលជូនមន្ទីរ និងក្រសួងតាមការកំណត់ (ឧបសម្ព័ន្ធទី២និងទី៣)។
- រៀបចំវិញ្ញាបនបត្របញ្ជាក់ការសិក្សាជូនអ្នកសិក្សា ដែលបញ្ចប់វគ្គបណ្តុះបណ្តាលដោយជោគជ័យ (ឧបសម្ព័ន្ធទី៧)។

## ៣.៦ តួនាទី និងភារកិច្ចរបស់អ្នកផ្តល់សេវាបណ្តុះបណ្តាល

- ផ្តល់ការបណ្តុះបណ្តាលជំនាញទាំងទ្រឹស្តី និងប្រតិបត្តិជាក់ស្តែង ប្រកបដោយវិជ្ជាជីវៈនិងគុណភាព
- អនុវត្តតាមលក្ខខណ្ឌក្នុងកិច្ចសន្យានិងគោលការណ៍ណែនាំរបស់ក្រសួង

- សហការរៀបចំកម្មវិធីសិក្សានិងឯកសារមេរៀនសម្រាប់បណ្តុះបណ្តាល (ឧបសម្ព័ន្ធទី៦)
- សហការរៀបចំផែនការបណ្តុះបណ្តាល តាមក្របខ័ណ្ឌពេលវេលា និងកាលវិភាគបណ្តុះបណ្តាល ដោយមានភាពបត់បែនតាមស្ថានភាពជាក់ស្តែង
- ស្រង់អវត្តមានអ្នកសិក្សាតាមម៉ោងសិក្សា
- ធ្វើតេស្តវាយតម្លៃសមត្ថភាពអ្នកសិក្សា
- រៀបចំបញ្ជីសម្រង់ពិន្ទុជាប់ធ្លាក់ជូនទៅសាលារៀន។

# ៤. ដំណើរការបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្នែម

## ៤.១ ការផ្តល់សេវាបណ្តុះបណ្តាល

ការបណ្តុះបណ្តាលត្រូវមាន៖

- រយៈពេលនៃការបណ្តុះបណ្តាលស្របទៅតាមជំនាញពី៣ខែ ដល់១២ខែ
- កម្មវិធីសិក្សានិងផែនការបណ្តុះបណ្តាលច្បាស់លាស់
- អ្នកសិក្សាយ៉ាងតិច១០នាក់ និងយ៉ាងច្រើន២០នាក់ ក្នុងមួយមុខជំនាញ
- ឯកសារមេរៀនច្បាស់លាស់ និងសម្ភារគ្រប់គ្រាន់សម្រាប់អ្នកសិក្សា
- សម្ភារៈសម្រាប់ប្រតិបត្តិត្រឹមត្រូវតាមមុខជំនាញ
- គ្រូបណ្តុះបណ្តាលដែលមានលក្ខណៈសម្បត្តិស្របតាមជំនាញ។

## ៤.២ លក្ខណៈសម្បត្តិអ្នកផ្តល់សេវាបណ្តុះបណ្តាល

គ្រូបណ្តុះបណ្តាលត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា លើមុខជំនាញដែលត្រូវបណ្តុះបណ្តាល(មានសញ្ញាបត្រ វិញ្ញាបនបត្រ ឬកស្តុតាងអនុវត្តជាក់ស្តែង)
- ទេពកោសល្យក្នុងការបណ្តុះបណ្តាលនិងចូលចិត្តធ្វើការជាមួយសិស្ស
- អត្តចរិតស្លូតបូត យុត្តិធម៌ និងស្មោះត្រង់ចំពោះការងារ
- បទពិសោធន៍ក្នុងការបណ្តុះបណ្តាលលើជំនាញ
- ចរិតលក្ខណៈជាអ្នកស្រាវជ្រាវនិងច្នៃប្រឌិត
- អ្នកផ្តល់សេវាបណ្តុះបណ្តាលជានារីត្រូវបានលើកទឹកចិត្ត។

## ៤.៣ ការជ្រើសរើសសិស្សចូលរៀនជំនាញ

### ៤.៣.១ លក្ខខណ្ឌនៃការជ្រើសរើស

- ជាសិស្សកំពុងសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិ
- ជាសិស្សដែលបានដាក់ពាក្យស្នើសុំចូលរួមទទួលការបណ្តុះបណ្តាល
- ជាសិស្សដែលប្រឈមនឹងការបោះបង់ការសិក្សា
- ជាសិស្សមានទេពកោសល្យលើជំនាញដែលខ្លួនបានស្នើសុំ

- សិស្សស្រី សិស្សក្រីក្រ និងសិស្សដែលមានពិការភាព (គិតតាមជំនាញដែលអាចសិក្សាបាន) ត្រូវបានផ្តល់អាទិភាព និងលើកទឹកចិត្ត
- ជ្រើសរើសសិស្សស្រី៥០% (ប្រសិនបើមានបេក្ខភាពគ្រប់គ្រាន់)។

### ៤.៣.២ ការផ្សព្វផ្សាយ

- ការផ្សព្វផ្សាយត្រូវធ្វើឡើងយ៉ាងតិច៣០ថ្ងៃ មុនការជ្រើសរើសសិស្សចូលរៀន
- លិខិតផ្សព្វផ្សាយបិទនៅវិទ្យាល័យគោលដៅ សាលាឃុំ/សង្កាត់ សហគមន៍ និងប្រជុំជន
- ចែកតាមផ្ទះគ្រួសារសិស្សក្រីក្រ តាមរយៈប្រធានភូមិ/ប្រធានក្រុម
- ផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា ដូចជា Facebook Telegram គេហទំព័រ...។

### ៤.៣.៣ របៀបនៃការជ្រើសរើស

- សិស្សដែលចាប់អារម្មណ៍ត្រូវដាក់ពាក្យស្នើសុំ
- ការជ្រើសរើសសិស្សត្រូវមានភាពបត់បែនតាមស្ថានភាពជាក់ស្តែងរបស់សាលានីមួយៗ តាមរយៈការធ្វើតេស្តសរសេរ ឬតេស្តផ្ទាល់មាត់ក្នុងករណីចំនួនបេក្ខជនលើសពីចំនួនដែលបានប្រកាសជ្រើសរើស
- គណៈកម្មការជ្រើសរើសត្រូវវិនិច្ឆ័យដោយផ្អែកតាមលក្ខខណ្ឌនៃការជ្រើសរើស
- ប្រកាស និងបិទផ្សាយលទ្ធផលនៃការជ្រើសរើសសិស្សត្រឹមមួយសប្តាហ៍យ៉ាងយូរ បន្ទាប់ពីការធ្វើតេស្ត។

# ៥. ក្របខណ្ឌការអនុវត្តកម្មវិធីសិក្សាជំនាញបន្ថែមផ្នែកស្ទែម

## ៥.១ កម្មវិធីសិក្សាជំនាញបន្ថែមផ្នែកស្ទែម

**មុខវិជ្ជាជំនាញស្ទែម**

ការកំណត់មុខជំនាញសម្រាប់បណ្តុះបណ្តាល សាលារៀនត្រូវសហការជាមួយភាគីពាក់ព័ន្ធ ត្រូវសិក្សាជំនាញស្របទៅតាមតម្រូវការអ្នកសិក្សា និងទីផ្សារការងារ តាមធនធានដែលមាននៅក្នុងសហគមន៍។ មុខវិជ្ជាជំនាញស្ទែមរួមមាន៖ ផ្នែកកុំព្យូទ័រ ផ្នែកអគ្គិសនី ផ្នែកមេកានិច ផ្នែកអេឡិចត្រូនិច ផ្នែកបសុវប្បកម្ម ផ្នែកក្សេត្រសាស្ត្រ ផ្នែកកែច្នៃអាហារ ផ្នែកអប់រំបំណិនជីវិត ផ្នែកសំណង់ ផ្នែកសិប្បកម្ម (ឧបសម្ព័ន្ធទី៨ ទី៩ និងទី១០) ឬជំនាញថ្មីផ្សេងទៀតដែលមិនមាននៅក្នុងឧបសម្ព័ន្ធ។

**រយៈពេលសិក្សា**

ពេលវេលានិងម៉ោងសិក្សាសម្រាប់មុខជំនាញនីមួយៗ ត្រូវរៀបចំដោយមានការឯកភាពគ្នារវាងសាលារៀននិងអ្នកផ្តល់សេវាបណ្តុះបណ្តាល។ សាលារៀននិងអ្នកផ្តល់សេវាបណ្តុះ បណ្តាលអាចរៀបចំម៉ោងសិក្សាបន្ថែមច្រើនជាងម៉ោងសិក្សាតាមការណែនាំ ដែលមានចែកក្នុងកម្មវិធី

សិក្សានេះ ដោយយោងទៅតាមតម្រូវការជាក់ស្តែងរបស់អ្នកសិក្សា និងស្ថានភាពនៃអ្នកផ្តល់សេវាបណ្តុះបណ្តាល ដើម្បីឈានសម្រេចគោលដៅបណ្តុះបណ្តាលជំនាញ។

**ក្របខ័ណ្ឌពេលវេលានិងកម្មវិធីសិក្សាជំនាញស្នែមមានៈ**

- ជំនាញសិក្សារយៈពេល ៣ខែ ចាប់ពី ៤៥ → ៥០ ម៉ោង ស្មើ ២ក្រេឌីត
- ជំនាញសិក្សារយៈពេល ៦ខែ ចាប់ពី ៩០ → ១០០ ម៉ោង ស្មើ ៤ក្រេឌីត
- ជំនាញសិក្សារយៈពេល ៩ខែ ចាប់ពី ១៣៥ → ១៥០ ម៉ោង ស្មើ ៦ក្រេឌីត
- ជំនាញសិក្សារយៈពេល ១២ខែ ចាប់ពី ១៨០ → ២០០ ម៉ោង ស្មើ ៨ក្រេឌីត

**កម្មវិធីសិក្សាជំនាញបន្ថែមផ្នែកស្នែមនេះ បែងចែកជាពីរផ្នែកគឺ ផ្នែកទ្រឹស្តីនិងផ្នែកប្រតិបត្តិៈ**

- ផ្នែកទ្រឹស្តី រយៈពេលសិក្សាមួយក្រេឌីតស្មើ១៥ម៉ោង
- ផ្នែកប្រតិបត្តិ រយៈពេលសិក្សាមួយក្រេឌីតស្មើ៣០ម៉ោង

**សម្គាល់ៈ** អ្នកសិក្សារៀនក្នុង១សប្តាហ៍៤ម៉ោង ក្នុង១ថ្ងៃ ១ឬ២ម៉ោង អាចបត់បែនតាមស្ថានភាពជាក់ស្តែង។

## ៥.២ វិធីសាស្ត្របណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្នែម

ការអនុវត្តកម្មវិធីសិក្សាជំនាញបន្ថែមផ្នែកស្នែម ត្រូវផ្តោតលើការអនុវត្តជាក់ស្តែងច្រើនជាងបទបង្ហាញក្នុងថ្នាក់ (ទ្រឹស្តីយ៉ាងច្រើន៣០% និងប្រតិបត្តិយ៉ាងតិច៧០%) រហូតដល់មានសមត្ថភាពឆ្លើយតបទៅនឹងលក្ខខណ្ឌបានកំណត់ក្នុងកម្មវិធី ដើម្បីធានាឱ្យសិស្សទទួលបាននូវសមត្ថភាពជំនាញជាក់លាក់សម្រាប់លើកកម្ពស់ជីវភាពរស់នៅ និងជំរុញទឹកចិត្តបន្តការសិក្សាផ្នែកស្នែមនៅឧត្តមសិក្សា។ ការសិក្សាទ្រឹស្តីផ្សារភ្ជាប់ទៅនឹងអនុវត្តជាក់ស្តែងក្នុងបន្ទប់ពិសោធន៍ បន្ទប់ប្រតិបត្តិ រោងជាង កសិដ្ឋាន ការដ្ឋាន ឬកន្លែងប្រកបអាជីកម្មផ្ទាល់របស់គ្រូបណ្តុះបណ្តាល ដោយផ្សារភ្ជាប់ខ្លឹមសារមេរៀនទៅនឹងការប្រតិបត្តិឬជីវភាពរស់នៅប្រចាំថ្ងៃ។ ការបណ្តុះបណ្តាលអាចប្រើប្រាស់វិធីសាស្ត្រចម្រុះ ដើម្បីជំរុញឱ្យការសិក្សាតាមបែបសកម្មនិងមានភាពជាក់ស្តែង។ ការបណ្តុះបណ្តាលនេះ ផ្តល់ឱ្យអ្នកសិក្សាធ្វើការងារជាបុគ្គលឬជាក្រុម ដើម្បីពិភាក្សា វិភាគ និងរិះរកបច្ចេកទេសថ្មីៗសម្រាប់ជំនាញស្នែម ដែលជាតម្រូវការការងារនៅក្នុងសហគមន៍ផ្ទាល់។ ការទស្សនាវិជ្ជអូ និងការធ្វើទស្សនកិច្ចសិក្សា គួរត្រូវបានជំរុញអនុវត្តដើម្បីបង្កើតគំនិតគ្រប់គ្រងអាជីវកម្មនិងទទួលបាននូវបទពិសោធន៍។

ការអនុវត្តកម្មវិធីសិក្សាជំនាញបន្ថែមផ្នែកស្នែម ផ្តោតលើគោលការណ៍នៃការបណ្តុះបណ្តាល ដូចខាងក្រោមៈ

**គោលការណ៍ទី១**

ការបណ្តុះបណ្តាល គឺជាសកម្មភាពសម្របសម្រួលការរៀនរបស់សិស្សដើម្បីឱ្យពួកគេទទួលបានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដោយប្រើប្រាស់វិធីសាស្ត្រចម្រុះស្របតាមស្ថានភាពអ្នកសិក្សា។

**គោលការណ៍ទី២**

ការបណ្ដុះបណ្ដាល គឺជាសកម្មភាពជួយ និងលើកទឹកចិត្តអ្នកសិក្សាឱ្យចេះរបៀបរៀនដោយខ្លួនឯងយ៉ាងសកម្ម មានប្រសិទ្ធភាព និងទទួលខុសត្រូវ ដើម្បីឈ្វេងយល់ ធ្វើវិចារ សហការ អង្កេត និងការអនុវត្តចំណេះដឹងសម្រាប់ការសិក្សា និងការរស់នៅប្រចាំថ្ងៃ ។

**គោលការណ៍ទី៣**

ការបណ្ដុះបណ្ដាលត្រូវបន្តពង្រឹង និងពង្រីកចំណេះដឹង បទពិសោធន៍ ទេពកោសល្យ និងចំណាប់ចំណូលចិត្តរបស់សិស្ស ដើម្បីឱ្យពួកគេស្រលាញ់ និងផ្ដល់តម្លៃដល់ការសិក្សាជំនាញស្នែម និងត្រូវផ្ដោតសំខាន់លើការប្រតិបត្តិជាក់ស្ដែងតាមជំនាញនីមួយៗ។

**គោលការណ៍ទី៤**

ការបណ្ដុះបណ្ដាលត្រូវតែផ្សារភ្ជាប់ទៅនឹងបរិស្ថានជុំវិញ តាមរយៈការប្រើប្រាស់វិធីសាស្ត្រ និងសម្ភារឧបទេសរួមទាំងបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្បូរបែប។

## ៥.៣ ការវាយតម្លៃកម្មវិធីសិក្សាជំនាញបន្ថែមផ្នែកស្ទែម

### ៥.៣.១ ការវាយតម្លៃការបង្រៀននិងរៀន

ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សត្រូវផ្ដោតទៅលើ វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។ ការវាយតម្លៃជាដំណើរការជានិរន្តរ៍សម្រាប់ប្រមូល វិភាគ និងឆ្លុះបញ្ចាំង ភស្តុតាងអំពីកម្រិតនៃសមត្ថភាពរបស់សិស្ស ក្រោយពីដំណើរការបង្រៀននិងរៀនទាំងផ្នែកទ្រឹស្ដី និងការប្រតិបត្តិ។ ការវាយតម្លៃគឺសំដៅរកព័ត៌មានឬភស្តុតាង ដើម្បីសន្និដ្ឋាន សម្រេចចិត្ត រិះរកវិធី និងផ្ដល់ធាតុចូលជួយដល់ការកែលម្អដំណើរការរៀនរបស់សិស្ស និងដំណើរការបង្រៀនរបស់គ្រូឱ្យឆ្លើយតបនឹងសមត្ថភាពរំពឹងទុកនៃកម្មវិធីសិក្សា។

លទ្ធផលនៃការវាយតម្លៃនឹងត្រូវប្រើប្រាស់ ដើម្បីកែលម្អក្នុងការបណ្ដុះបណ្ដាលឱ្យមានប្រសិទ្ធភាព គណនេយ្យភាព និងឆ្លើយតបនឹងវត្ថុបំណងគោលនយោបាយអប់រំ។ លទ្ធផលនៃការវាយតម្លៃនឹងត្រូវបានប្រើប្រាស់សម្រាប់៖

- លើកទឹកចិត្តឱ្យអ្នកសិក្សាប្រឹងរៀនបន្តដោយកែលម្អចំណុចខ្សោយទាក់ទងនឹងឥរិយាបថ ទម្លាប់ វិធី និងសកម្មភាពរៀនរបស់សិស្ស
- ប្រមូលព័ត៌មានមូលដ្ឋាន និងភស្តុតាងឱ្យគ្រូយកទៅវាស់ស្ទង់ប្រសិទ្ធភាពនៃការបង្រៀន និងកែលម្អឥរិយាបថ ទម្លាប់ វិធី និងសកម្មភាពបង្រៀន
- ចែករំលែកដល់មាតាបិតា និងអាណាព្យាបាល និយោជក និងសាធារណៈអំពីការសម្រេចលទ្ធផលសិក្សារបស់សិស្ស និងប្រសិទ្ធភាពនៃការគ្រប់គ្រងកម្មវិធី។

### ៥.៣.២ ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស

អ្នកសិក្សានឹងទទួលបាននូវគុណវុឌ្ឍិ ដោយមានចំណេះដឹងគ្រប់គ្រាន់ក្នុងការអនុវត្តនីតិវិធី និងបទបញ្ញាតិដែលកំណត់ក្នុងមុខរបរ សមត្ថភាពក្នុងការអនុវត្តកិច្ចការស្របតាមនីតិវិធីឬការ

ណែនាំផ្ទាល់ សមត្ថភាពបំពេញកិច្ចការប្រកបដោយការទទួលខុសត្រូវ សមត្ថភាពយល់ដឹងដែលឆ្លើយតបតាមការណែនាំនិងនីតិវិធីមូលដ្ឋាន សមត្ថភាពក្នុងការប្រមូលព័ត៌មានតាមរយៈផ្ទាល់មាត់និងរបាយការណ៍ជាសំណេរ និងសមត្ថភាពក្នុងការអនុវត្តនីតិវិធីងាយៗ។

លទ្ធផលសិក្សារំពឹងទុករបស់សិស្សកំណត់ដោយសំណុំសមត្ថភាពធំៗពីរ គឺសមត្ថភាពមូលដ្ឋាននិងសមត្ថភាពស្នូល។ ការវាយតម្លៃគឺជាការវាស់ស្ទង់លើវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទារបស់អ្នកសិក្សា ដើម្បីបញ្ជាក់ពីលទ្ធផលសិក្សា និងឆ្លុះបញ្ចាំងពីការដឹកនាំសកម្មភាពសិក្សារបស់អ្នកផ្តល់សេវាបណ្តុះបណ្តាល។ ការវាយតម្លៃលទ្ធផលសិក្សារបស់អ្នកសិក្សា គួរផ្តោតលើចំណុចសំខាន់ៗដូចជា ចំណេះដឹង ជំនាញក្នុងការគិត ជំនាញអន្តរបុគ្គល និងការទទួលខុសត្រូវ ជំនាញផ្នែកលេខនព្វន្ត ព័ត៌មានវិទ្យានិងទំនាក់ទំនង និងជំនាញចិត្តចលនា។

**ការវាយតម្លៃលើចំណេះដឹង៖**

- មានចំណេះដឹងកម្រិតមូលដ្ឋាន ទាក់ទងនឹងកិច្ចការអាជីព ដែលបានកំណត់ក្នុងបរិបទការងាររួមមានការអនុវត្តនីតិវិធី បទបញ្ញត្តិ និងគោលគំនិតបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស និងតម្រូវការទីផ្សារ។

**ការវាយតម្លៃលើជំនាញក្នុងការគិត៖**

- ប្រើប្រាស់ចំណេះដឹងដែលបានពីការសិក្សា និងបទពិសោធន៍
- ធ្វើការសម្រេចចិត្ត និងដោះស្រាយបញ្ហាដែលកើតមានក្នុងពេលអនុវត្ត។

**ការវាយតម្លៃលើជំនាញអន្តរបុគ្គលនិងការទទួលខុសត្រូវ៖**

- បំពេញភារកិច្ចប្រកបដោយការទទួលខុសត្រូវតាមការណែនាំបច្ចេកទេស
- ទទួលខុសត្រូវចំពោះលទ្ធផលការងាររបស់ខ្លួន។

**ការវាយតម្លៃលើជំនាញផ្នែកលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង៖**

- អាចគណនាមាត្រដ្ឋានបច្ចេកទេសនៃជំនាញរបស់ខ្លួន ការផលិត ការលក់ និងការចំណាយ
- អាចបកស្រាយ ភ្ជាប់បទពិសោធន៍សិក្សាទៅនឹងអាជីវកម្មខ្នាតតូចឬធំ
- អាចធ្វើទំនាក់ទំនងតារយៈផ្ទាល់មាត់ សំណេរ ឬបំពេញទម្រង់ផ្សេងៗដែលពាក់ព័ន្ធទៅនឹងការងារបច្ចេកទេសរបស់ខ្លួន។

**ការវាយតម្លៃលើជំនាញចិត្តចលនា៖**

- មានជំនាញមូលដ្ឋានក្នុងការប្រើប្រាស់ឧបករណ៍ស្តង់ដាក្នុងអាជីពជំនាញ។

## ៦. ថវិកាគាំទ្រការបណ្តុះបណ្តាល

ក្រសួងអប់រំ យុវជន និងកីឡា នឹងផ្តល់ថវិកាគាំទ្រដំណើរការបណ្តុះបណ្តាលនេះយ៉ាងច្រើន១០,០០០ ដុល្លារ (ដប់ពាន់ដុល្លារគត់) ក្នុងមួយវិទ្យាល័យធនធាន សម្រាប់ផ្តល់ សេវាបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្នែម។ ចំណាយលើសោហ៊ុយបណ្តុះបណ្តាលនឹងប្រែប្រួលទៅតាមតំបន់ផ្សេងៗគ្នា និងអាស្រ័យលើការពិភាក្សាគ្នារវាងគណៈកម្មការដឹកនាំគ្រប់គ្រងការបណ្តុះបណ្តាលនិងអ្នកផ្តល់សេវាបណ្តុះបណ្តាល។

### ៦.១ ការរៀបចំផែនការថវិកាប្រចាំឆ្នាំ

- គណៈកម្មការដឹកនាំគ្រប់គ្រងការបណ្តុះបណ្តាលត្រូវរៀបចំផែនការថវិកាប្រចាំឆ្នាំឱ្យបាន៤ខែយ៉ាងតិច មុនការចាប់ផ្តើមអនុវត្តកម្មវិធីបណ្តុះបណ្តាល
- ប្រធានគណៈកម្មការដឹកនាំគ្រប់គ្រងការបណ្តុះបណ្តាល ត្រូវចុះហត្ថលេខាលើផែនការ ថវិកាប្រចាំឆ្នាំ រួចបញ្ជូនមកនាយកគម្រោង តាមរយៈនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ដើម្បីស្នើសុំការអនុម័ត។

### ៦.២ ការទូទាត់ចំណាយ

ការបណ្តុះបណ្តាលដែលមានរយៈពេលខ្លី (ក្រោម៣ខែ)៖ ក្រោយពេលសកម្មភាពដែលបានព្រមព្រៀងត្រូវបានបញ្ចប់ អ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញ ត្រូវរៀបចំវិកយបត្រទូទាត់ចំណាយ រួចបញ្ជូនមកអង្គភាពសម្របសម្រួលគម្រោង (PCU) តាមរយៈនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ដើម្បីស្នើសុំការទូទាត់ចំណាយ។ អង្គភាពហិរញ្ញវត្ថុគម្រោង នឹងធ្វើការទូទាត់ជូន តាមរយៈការផ្ទេរប្រាក់តាមប្រព័ន្ធធនាគារ ឬតាមរយៈមូលប្បទានបត្រ ។ ដោយឡែក សម្រាប់វគ្គបណ្តុះបណ្តាលដែលមានរយៈពេលមធ្យម (ចាប់ពី៣ខែ ទៅ ៦ខែ) ឬវគ្គបណ្តុះបណ្តាលរយៈពេលវែង (៦ខែ ដល់ ១២ខែ) ការទូទាត់ចំណាយ អាចធ្វើទៅតាមដំណាក់កាលតាមការព្រមព្រៀងរវាងគណៈកម្មការដឹកនាំគ្រប់គ្រងការបណ្តុះបណ្តាលនិងអ្នកផ្តល់សេវាបណ្តុះបណ្តាល។

## ៧. យន្តការអនុវត្ត

ការផ្តល់សេវាបណ្តុះបណ្តាលនៅតាមវិទ្យាល័យធនធាន ត្រូវអនុវត្តដូចខាងក្រោម៖

- បង្កើតគណៈកម្មការដឹកនាំគ្រប់គ្រងការបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្វែម
- សិក្សាជំនាញស្របតាមតម្រូវការអ្នកសិក្សា និងទីផ្សារការងារ ស្របតាមធនធានដែលមាននៅក្នុងសហគមន៍ ដើម្បីកំណត់ជំនាញដែលត្រូវបណ្តុះបណ្តាល (ឧបសម្ព័ន្ធទី៨ ទី៩ និងទី១០)
- ជ្រើសរើសអ្នកផ្តល់សេវាបណ្តុះបណ្តាលតាមជំនាញដោយផ្តល់អាទិភាពដល់សហគ្រាស ក្រុមហ៊ុន គ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ សាកលវិទ្យាល័យ ដែលមាននៅក្នុងមូលដ្ឋាន
- ក្នុងករណីនៅក្នុងមូលដ្ឋានមិនមានអ្នកផ្តល់សេវាបណ្តុះបណ្តាលតាមមុខជំនាញ គណៈកម្មការដឹកនាំគ្រប់គ្រងការបណ្តុះបណ្តាលអាចពិភាក្សាពីការផ្លាស់ប្តូរជំនាញប្រហាក់ប្រហែល ឬជំនាញថ្មី ដែលឆ្លើយតបទៅនឹងតម្រូវការអ្នកសិក្សា
- ជ្រើសរើសអ្នកសិក្សានៅតាមវិទ្យាល័យគោលដៅ ដោយអ្នកសិក្សាត្រូវបំពេញពាក្យសុំចូលរៀន និងកិច្ចសន្យាសិក្សាមិនគិតថ្លៃ (ឧបសម្ព័ន្ធ៤)
- រៀបចំផែនការ កម្មវិធី និងកាលវិភាគបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្វែម បត់បែនទៅតាមតម្រូវការរបស់អ្នកសិក្សា និងអ្នកផ្តល់សេវានៅតាមសាលានីមួយៗ

- កំណត់ទីតាំងការបណ្តុះបណ្តាល អាស្រ័យទៅតាមស្ថានភាពជាក់ស្តែងនៃតម្រូវការប្រើប្រាស់សម្ភារៈ ឧបករណ៍ប្រតិបត្តិ និងអគ្គិសនីដែលគណៈគ្រប់គ្រងវគ្គ និងអ្នកបណ្តុះបណ្តាលបានឯកភាពគ្នា
- អនុវត្តដំណើរការវគ្គបណ្តុះបណ្តាលតាមផែនការប្រកបដោយប្រសិទ្ធភាពខ្ពស់
- ត្រួតពិនិត្យតាមដាននិងវាយតម្លៃវគ្គបណ្តុះបណ្តាល
- រៀបចំរបាយការណ៍ទៅតាមដំណាក់កាល មុនចាប់ផ្តើមវគ្គ វឌ្ឍនភាពនៃដំណើរការវគ្គ និងបញ្ចប់វគ្គ( ឧបសម្ព័ន្ធទី២ )។

## ៨. ផែនការសកម្មភាពដំណើរការប្រតិបត្តិការផ្តល់សេវាបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្នែម នៅវិទ្យាល័យធនធាន

| សកម្មភាពគោល | សកម្មភាពរង | ក្របខណ្ឌពេលវេលា | ថវិកា | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| -ការរៀបចំផែនការ | -ការរៀបចំគណកម្មការ<br>-ការសិក្សាតម្រូវការជំនាញក្នុងសហគមន៍<br>-ការសិក្សាគ្រូបណ្តុះបណ្តាលក្នុងសហគមន៍<br>-ការសិក្សាតម្រូវការជំនាញរបស់សិស្ស | -រៀបចំ៣ខែមុនដំណើរការវគ្គ | -១០០០០ ដុល្លាក្នុង១ឆ្នាំ និងរៀបចំចំណាយតាមវគ្គសិក្សានីមួយៗ | -មន្ទីរអេយក.រាជធានី/ខេត្ត<br>-ការិ.អប់រំអេយក.ក្រុង/ស្រុក/ខណ្ឌ<br>-វិទ្យាល័យធនជាន |
| | -ការរៀបចំផែនការចំណាយ (គ្រូបណ្តុះបណ្តាល ការងារគម្រោងរបស់សិស្ស សម្ភារឧបទ្ទេស និងផ្សេងៗ) | -រៀបចំ៣ខែមុនដំណើរការវគ្គ | | -មន្ទីរអេយក. រាជធានី/ខេត្ត<br>-ការិ.អប់រំអេយក.ក្រុង/ស្រុក/ខណ្ឌ<br>-វិទ្យាល័យធនជាន |
| | -ការរៀបចំផែនការផ្សព្វផ្សាយនិងជ្រើសរើសសិស្សនិងគ្រូបណ្តុះបណ្តាល | -រៀបចំ៣ខែមុនដំណើរការវគ្គ | | -មន្ទីរអេយក.រាជធានី/ខេត្ត<br>-ការិ.អប់រំអេយក.ក្រុង/ស្រុក/ខណ្ឌ<br>-វិទ្យាល័យធនជាន |
| -ដំណើរការបណ្តុះបណ្តាល | -ការអនុវត្តកម្មវិធីសិក្សា<br>-ការប្រើប្រាស់សម្ភារពិសោធន៍ឬប្រតិបត្តិ | -រយៈពេលសិក្សា៣ខែ ៦ខែ ៩ខែ ១២ខែ | | -គ្រូបណ្តុះបណ្តាល<br>-នាយកវិទ្យាល័យធនជាន |

| | | | | |
|---|---|---|---|---|
| | -ការកំណត់ទីកន្លែងបណ្តុះបណ្តាល<br>-ការប្រើប្រាស់វិធីសាស្រ្តបង្រៀនបែបចំរុះ | | | |
| -ការពិនិត្យតាមដាននិងវាយតម្លៃ | -ការដឹកនាំនិងគ្រប់គ្រង<br>-ការបង្រៀននិងរៀន<br>-ការផ្តល់ព័ត៌មានត្រលប់<br>-លទ្ធផលការសិក្សាសិស្ស<br>-ការបញ្ចប់វគ្គ<br>-ការរៀបចំរបាយការណ៍ | -ពិនិត្យតាមដាននិងវាយតម្លៃតាមវគ្គសិក្សានីមួយៗ | | -ក្រសួងអយក.<br>-ក្រុមការងារគម្រោងADB<br>-មន្ទីរអេយក.រាជធានី/ខេត្ត<br>-ការិ.អប់រំអេយក.ក្រុង/ស្រុក/ខណ្ឌ<br>-នាយកវិទ្យាល័យធនធាន |

## ៩. ការពិនិត្យតាមដាន និងវាយតម្លៃ

ក្រសួងអប់រំ យុវជន និងកីឡា គណៈគ្រប់គ្រងគម្រោង មន្ទីរអប់រំ យុវជន និងកីឡា នឹងធ្វើការពិនិត្យតាមដាននិងវាយតម្លៃ ព្រមទាំងជួយតម្រង់ទិសការអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្ទែមដល់វិទ្យាល័យធនធាន និងអ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញ តាមរយៈយន្តការនានាដែលមានស្រាប់។ ការពិនិត្យតាមដាន និងជួយតម្រង់ទិស ផ្តោតសំខាន់លើ៖

- ការគ្រប់គ្រង និងអនុវត្តកម្មវិធីបណ្តុះបណ្តាល
- សកម្មភាពបង្រៀននិងរៀន
- ការប្រើប្រាស់ថវិកា និងការចុះកិច្ចសន្យា
- ការវាយតម្លៃសមត្ថភាពអ្នកសិក្សាដើម្បីទទួលស្គាល់ និងចេញវិញ្ញាបនបត្រ។

## ១០. យន្តការអនុវត្តការងារបរិបទជំងឺកូវីដ-១៩

- រាល់ការផ្សព្វផ្សាយដូចជា ការកំណត់មុខជំនាញ ជ្រើសរើសគ្រូ ជ្រើសរើសសិស្ស ការណែនាំនិងសកម្មភាពនៃការផ្តល់សេវាបណ្តុះបណ្តាលជំនាញស្ទែមនៅតាមសាលានិងដល់គ្រប់អ្នកពាក់ព័ន្ធតាមប្រព័ន្ធអនឡាញដូចជា Facebook Telegram គេហទំព័រ...។
- គណកម្មការសហការជាមួយគ្រូបណ្តុះបណ្តាល ដើម្បីរៀបចំផែនការ កម្មវិធីសិក្សា និងកាលវិភាគទៅតាមមុខជំនាញនីមួយៗតាមប្រព័ន្ធអនឡាញ
- រាល់កិច្ចប្រជុំពិភាក្សាទាំងអស់អនុវត្តតាមប្រព័ន្ធអនឡាញ
- ធ្វើតេស្តវាយតម្លៃសមត្ថភាពអ្នកសិក្សាតាមប្រព័ន្ធអនឡាញដូចជា ការថតជាវីឌីអូ ឬបង្ហាញផ្ទាល់តាម Zoom, Google Meet...
- ត្រួតពិនិត្យតាមដាននិងវាយតម្លៃវគ្គបណ្តុះបណ្តាលត្រូវធ្វើតាមប្រព័ន្ធអនឡាញ កិច្ចប្រជុំ ការផ្តល់របាយការណ៍ ផ្តល់ជាវីឌីអូ រូបភាពសិស្សកំពុងសិក្សា និងលទ្ធផលតេស្តរបស់សិស្ស...

- រៀបចំរបាយការណ៍ទៅតាមដំណាក់កាល មុនចាប់ផ្តើមវគ្គ វឌ្ឍនភាពនៃដំណើរការវគ្គ និងបញ្ចប់វគ្គត្រូវបញ្ជូនតាមប្រព័ន្ធអនឡាញ
- ទីកន្លែងបណ្តុះបណ្តាលត្រូវគោរពតាមគោលការណ៍ប្រតិបត្តិSOP និងអនុវត្តន៍វិធានការ៣កុំ ៣ការពារ។

## ១១. សន្និដ្ឋាន

តាមរយៈលទ្ធផលនៃការចុះស្ទង់មតិជាមួយនាយកសាលា សិស្ស មាតាបិតាសិស្ស និងសហគ្រាស ផ្នែកឯកជននៅក្នុងមូលដ្ឋាននៃវិទ្យាល័យធនធានបានបង្ហាញឱ្យឃើញថា សិស្សភាគច្រើនចាប់អារម្មណ៍យ៉ាងខ្លាំងលើជំនាញស្ទែម និងចង់សិក្សាលើមុខវិជ្ជាជំនាញដែលអាចជួយដោះស្រាយជីវភាព បំពេញតាមតម្រូវការទីផ្សារការងារនិងតម្រូវការក្នុងសហគមន៍។ អ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញបានពេញចិត្ត សហការ ចូលរួមគាំទ្រជាខ្លាំងក្នុងការផ្តល់សេវាបណ្តុះបណ្តាលជំនាញឱ្យទទួលបានជោគជ័យ។ គណៈគ្រប់គ្រងសាលា ការិយាល័យអប់រំយុវជន និងកីឡានៃរដ្ឋបាលស្រុក ក្រុង ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ក៏បង្ហាញពីឆន្ទៈគាំទ្រ ហើយអាចសន្និដ្ឋានថាការបណ្តុះបណ្តាលជំនាញស្ទែមនេះ ពិតជាបានជួយលើកកម្ពស់ដល់ជីវភាពរស់នៅប្រចាំថ្ងៃ និងសេដ្ឋកិច្ចគ្រួសាររបស់សិស្ស បំពេញបាននូវតម្រូវការទីផ្សារការងារនិងសហគមន៍ ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រនិងការធ្វើចំណាកស្រុក។

# បទានុក្រម

- បច្ចេកវិទ្យា (ន) វិជ្ជាខាងវិទ្យាសាស្ត្រ ជំនាញមួយប្រភេទដែលកើតឡើងពីការរកឃើញជាក់ស្តែង។
- វិស្វកម្ម (ន) ជាអ្នកដោះស្រាយបញ្ហា អ្នកដែលធ្វើការស្រាវជ្រាវច្នៃប្រឌិត និងបង្កើតនូវឧបករណ៍ថ្មីៗ ដើម្បីធ្វើឱ្យជីវិតរស់នៅរបស់យើងឱ្យកាន់តែប្រសើរឡើង។
- ទេពកោសល្យ (ន) សមត្ថភាពឈ្លាសវៃ ភាពប្លែកពីគេ ភាពប៉ិនប្រសប់បំផុតរបស់មនុស្សក្នុងការធ្វើអ្វីមួយ ឬដែលកើតចេញពីការច្នៃប្រឌិតខ្លួនឯង។
- ជំនាញស្ទែម (ន) ការច្នៃប្រឌិតថ្មីដែលមានធាតុផ្សំពី វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម គណិតវិទ្យា។
- គំនិតច្នៃប្រឌិត (ន) ចេញមកពីចរិកលក្ខណៈផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ ការស្រមើស្រមៃ ភាពដាច់តែឯងក៏ដូចជាការធ្វើការជាក្រុមគឺជាគន្លឹះគោលនៃការស្វែងរកនិងការបង្កើតគំនិតថ្មី។
- ការច្នៃប្រឌិត (ន) ជារបៀបមួយក្នុងការប្រគុំគំនិតបញ្ញា សម្រាប់ឆ្លើយតបទៅនឹងបញ្ហាធំៗដែលកំពុងវិវត្តយ៉ាងលឿននៅក្នុងពិភពលោកដែលយើងទាំងអស់គ្នាកំពុងរស់នៅ។
- លទ្ធផលសិក្សា (ន) ជាសេចក្តីថ្លែងនូវអ្វីដែលអ្នកសិក្សាចេះ យល់ ដឹង អាចធ្វើក្រោយបញ្ចប់ការសិក្សាតាមរយៈលក្ខណវិនិច្ឆ័យស្នាដៃការងារផ្អែកលើចំណេះដឹង ជំនាញ អាកប្បកិរិយា និងសមត្ថភាព។
- កម្មវិធីសិក្សា (ន) ជាសំណុំការងារទូទៅនៃការអភិវឌ្ឍន៍កម្មវិធីសិក្សា រួមមានការកំណត់គោលដៅ ខ្លឹមសារ វិធីសាស្ត្រ ព្រមទាំងការវាយតម្លៃនិងសម្ភារនៃការបណ្តុះបណ្តាល។
- បណ្តុះបណ្តាល (កិ) ការផ្តល់នូវចំណេះដឹង បំពេញបន្ថែមនូវវិជ្ជាជីវៈឱ្យបានគ្រប់គ្រាន់។
- វិជ្ជាសម្បទា (កិ) ចំណេះដឹងដែលសិក្សានុសិស្សទទួលបានពីកម្មវិធីអប់រំហើយអាចយកទៅអនុវត្តក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួន។
- បំណិនសម្បទា (កិ) អត្តចរិត មនោសញ្ចេតនា ដែលសិស្សចេះប្រកាន់យកក្នុងស្ថានភាពជាក់ស្តែងមួយដើម្បីដាក់ចេញនូវវិធានការឬដំណោះស្រាយសមស្របស្មើភាពជាមួយដៃគូ។
- ចរិយាសម្បទា (កិ) ភាពប៉ិនប្រសប់ដែលសិស្សានុសិស្សទទួលបានពីកម្មវិធីសិក្សាអប់រំ ហើយអាចយកទៅអនុវត្តក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួនបាន។
- ទីផ្សារការងារ (ន) ទីកន្លែងដែលមានតម្រូវការអ្នកជំនាញវិជ្ជាជីវៈច្បាស់លាស់។
- USESDP II (ន) គម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២
- ADB (ន) ធនាគារអភិវឌ្ឍន៍អាស៊ី

# ឧបសម្ព័ន្ធ

**(ឧបសម្ព័ន្ធទី១)**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**មន្ទីរអប់រំ យុវជន និងកីឡាខេត្ត** ..............................
**វិទ្យាល័យ** ...............................................................

**កិច្ចសន្យាស្តីពី**
**ការផ្តល់សេវាបណ្តុះបណ្តាលមុខជំនាញស្ទែម (STEM SKILL)**

